# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ខែមីនា-មេសា ឆ្នាំ២០១៨ / March-April 2018**

**មាតិកា**

ទំព័រ


**ខ្លឹមសារសង្ខេប/Executive summary** ២

**១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** ៤

១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index ៤

១.២. វិស័យហិរញ្ញវត្ថុ/Finance ៥

១.៣. វិស័យពាណិជ្ជកម្ម/Trade ៦

១.៤. ការអនុវត្តថវិកា/Budget execution ៧

១.៥. វិស័យវិនិយោគឯកជន/Private investment ៨

១.៦. វិស័យទេសចរណ៍/Tourism ៩

១.៧. វិស័យសំណង់/Construction ៩

**២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices** ១០

២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) ១០

២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) ១០

២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) ១០

**៣. ឧបសម្ព័ន្ធ** ១២

## ខ្លឹមសារសង្ខេប / Executive summary

**១.** កំណើនសន្ទស្សន៍ថ្លៃទំនិញជាមធ្យមក្នុងត្រីមាសទី១ ឆ្នាំ២០១៨នេះ មានអត្រា ២,២% ទាបជាងត្រីមាសទី១ ឆ្នាំ២០១៧ (៤,២%) ដោយសារកំណើនទាបនៃសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ដែលកំណើនជាមធ្យម ១,៩% ទាបជាងត្រីមាសទី១ ឆ្នាំ២០១៧កន្លងទៅ (៥,៩%) ក្នុងនោះ ក្រុមទំនិញដែលថមថយកំណើនគួរឱ្យកត់សម្គាល់រួមមាន សាច់ បន្លែ និងផ្លែឈើស្រស់។

**២.** គិតត្រឹមខែមីនា ឆ្នាំ២០១៨ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៧០.៣០០ប៊ីលានរៀល បានកើនឡើង ១,៤%ធៀបនឹងខែមុន និង ២១,៦%ធៀបនឹង១ឆ្នាំមុន។ ការផ្តល់ឥណទានដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុមានចំនួន ៥៥,៦២៣ប៊ីលានរៀល (៧៩% នៃឥណទានសរុប) ក្នុងនោះឥណទានផ្តល់ទៅវិស័យសេវាកម្ម ៦៦,៧%, កសិកម្ម ១២,៨%, សំណង់ ១២,៥% និងឧស្សាហកម្ម ៨%។ អត្រាការប្រាក់ធនាគារពាណិជ្ជចំពោះកម្ចីជាប្រាក់រៀល និងដុល្លារស្មើនឹង ១២,០៣% និង១១,៤៥% បានថយចុះបន្តិចធៀបខែកុម្ភៈកន្លងទៅ។

រូបិយវត្ថុទូទៅ(M2) បានបន្តកើនឡើងក្នុងដើមឆ្នាំ២០១៨នេះ, គិតត្រឹមខែមីនា ឆ្នាំ២០១៨ បានកើនដល់ ៧៥.១៦៤ ប៊ីលានរៀល បានកើនឡើង ២,៧% ធៀបនឹងខែមុន និង ២៤,១% ធៀបនឹង១ឆ្នាំមុន, ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានចំនួន ៦៣.៤៧៩ប៊ីលានរៀល បានកើនឡើង ២៤%ធៀបនឹង១ឆ្នាំមុន។

**៣.** ក្នុងខែមេសា ឆ្នាំ២០១៨ តម្លៃជួញដូរលើទីផ្សារមូលបត្រកម្ពុជា (CSX) មានចំនួន ៧២៥លានរៀល បានកើនឡើង ១២៤%ធៀបទៅនឹងខែមីនាកន្លងទៅ (៣២២លានរៀល) ក្នុងនោះតម្លៃជួញដូររបស់កំពង់ផែស្វយ័តភ្នំពេញ (PPAP) មាន ៦៦,៥%, កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) មាន ១៥,៦%, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) មាន ១២,២%, ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSP) មាន ៤,៨% និងក្រុមហ៊ុន Grand Twins International Cambodia Plc (GTI) មាន ០,៩%។

**៤.** ស្ថានភាពវិវត្តផ្នែកពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជានៅតែមានសន្ទុះខ្លាំងក្នុងខែមីនា ឆ្នាំ២០១៨។ ភាពប្រសើរឡើងនេះ បានរុញកំណើនទំហំទឹកប្រាក់នាំចេញសរុបក្នុងត្រីមាសទី១នេះរហូតដល់ ២.៨៤៧លានដុល្លារ ឬកើនឡើង ១២,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ រីឯទំហំទឹកប្រាក់នាំចូលសរុបក្នុងត្រីមាសទី១ ឆ្នាំ២០១៨មានចំនួន ៣.៩៥១លានដុល្លារ កើនឡើង ២៤,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើនការនាំចូលខ្ពស់នេះ បានបង្ហាញពីការកើនឡើងនៃតម្រូវការប្រើប្រាស់ក្នុងស្រុក និងវត្ថុធាតុដើមបម្រើឱ្យឧស្សាហកម្មនាំចេញ។

**៥.** តាមទិន្នន័យបឋមពីរតនាគារជាតិ នៅរយៈពេល៣ខែដើមឆ្នាំ២០១៨នេះ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលសរុបបានចំនួន ៤.០៨៣,១៣ប៊ីលានរៀល គឺស្មើនឹង ២៣,១% និងចំណាយអនុវត្តបានចំនួន ៣.៣៦៣,៩៣ប៊ីលានរៀល ស្មើនឹង ១៤,៧%នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះចំណាយចរន្តអនុវត្តបានចំនួន ២.៨២៤,៣៩ប៊ីលានរៀល ស្មើនឹង ១៨,៤%។ ការអនុវត្តចំណាយមានលក្ខណៈល្អប្រសើរជាងឆ្នាំកន្លងទៅ ដោយសារ ការចូលរួមអនុវត្តរបស់អ្នកពាក់ព័ន្ធលើការកែទម្រង់នីតិវិធីចំណាយ ដែលមានលក្ខណៈងាយអនុវត្ត និងបុរេសកម្ម។ ជារួម លទ្ធផលនៃការអនុវត្តថវិការដ្ឋគឺបង្ហាញពីការខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីធានានូវប្រសិទ្ធភាពការអនុវត្តថវិកា។

**៦.** រយៈពេល ៤ខែដើមឆ្នាំ២០១៨នេះ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន ៤៦គម្រោង (ថយចុះ ១៩គម្រោង) និងមានទុនវិនិយោគសរុបចំនួន ៦០០លានដុល្លារអាមេរិក គឺបានកើនឡើងប្រមាណជាង ២ដងធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ ព្រមទាំងបង្កើតការងារបានប្រមាណ ៥១ពាន់កន្លែង។ ការវិនិយោគលើវិស័យកសិកម្មមាន ៦គម្រោង មានទុនវិនិយោគប្រមាណ ៣៥,១% នៃទុនវិនិយោគសរុប ដែលមានប្រភេទគម្រោងដូចជា រោងចក្រកសិ-ឧស្សាហកម្ម, រោងម៉ាស៊ីនកិនស្រូវ និងរោងចក្រកៅស៊ូ។

**៧.** រយៈពេល ៣ខែដើមឆ្នាំ២០១៨នេះ ចំនួនមកដល់នៃភ្ញៀវទេសចរអន្តរជាតិសរុបមានប្រមាណ ១.៧១១ពាន់នាក់ បានកើនឡើង ១៣,៩% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដែលភ្ញៀវទេសចរភាគច្រើនគឺជា ជនជាតិចិន, វៀតណាម, កូរ៉េ, ឡាវ, ថៃ និងសហរដ្ឋអាមេរិច។

**៨.** រយៈពេល ៤ខែដើមឆ្នាំ២០១៨ សំណើសុំសាងសង់សរុបមាន ១.១៧១គម្រោង មានការកើនឡើងគួរឱ្យកត់សម្គាល់ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (កើនឡើង ១៥១គម្រោង) ដែលភាគច្រើនគឺកើនឡើងលើប្រភេទសំណង់លំនៅដ្ឋាន និងពាណិជ្ជកម្ម។

**៩.** ក្នុងខែមេសា ឆ្នាំ២០១៨ ថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិនៅតែបន្តកើនឡើង នេះ*ដោយសារការកើនឡើងតម្រូវការប្រេងឆៅខ្លាំងនៅលើទីផ្សារពិភពលោក នាដើមត្រីមាសទី២នេះ ស្របពេលប្រទេសផលិតប្រេងឆៅ ដូចជាសហរដ្ឋអាមេរិក និងអ៊ីរ៉ង់ បានព្យាយាមបង្កើនគុណភាពប្រេងរបស់ខ្លួនពីគុណភាពធម្មតា (Regular) ទៅកម្រិតខ្ពស់ (Premium)។*

អង្ករនាំចេញ (ខ្ទេច ៥%) របស់កម្ពុជា មានការធ្លាក់ថ្លៃបន្តិច ធៀបនឹងខែមីនាកន្លងទៅ ដោយសារ ការប្រកួតប្រជែងថ្លៃអង្ករនាំចេញជាមួយប្រទេសក្នុងតំបន់ និងក្រៅតំបន់ ស្របពេលដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជាជំរុញការបញ្ចុះថ្លៃ និងបង្កើនគុណភាពអង្ករក្នុងគោលដៅទាក់ទាញការបញ្ជាទិញបន្ថែមពីប្រទេសដៃគូពាណិជ្ជកម្ម។ រីឯថ្លៃអង្ករនាំចេញរបស់ថៃ និងវៀតណាមមានការកើនឡើងដូចគ្នា ដោយសារទីផ្សារចិន និងអាហ្វ្រិកមានតម្រូវការអង្ករស និងអង្ករសម្រូបរបស់ថៃក្នុងត្រីមាសទី២នេះ យោងតាម National News Bureau of Thailand និង www.bangkokpost.com។ រីឯប្រទេសវៀតណាមបានទទួលការចុះកិច្ចសន្យាបញ្ជាទិញជាបន្តបន្ទាប់ពីប្រទេសដៃគូពាណិជ្ជកម្ម រួមមានប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី។

កៅស៊ូឆៅស្តង់ដារ TSR20 លើទីផ្សារអាស៊ី ថ្លៃ ១.៤៣០ដុល្លារ/តោន បានធ្លាក់ចុះ ១០ដុល្លារ/តោន ធៀបខែមុន ដោយសារការផ្គត់ផ្គង់កៅស៊ូធម្មជាតិលើសពីតម្រូវការលើទីផ្សារពិភពលោក ព្រមទាំងភាពតានតឹងពាណិជ្ជកម្មរវាងប្រទេសចិន និងសហរដ្ឋអាមេរិក។

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)


















# អតិផរណា រូបិយវត្ថុ និងទុនបម្រុងបរទេស (Inflation, M2 and Foreign Reserve)


















# អត្រាប្តូរប្រាក់ (Exchange Rate)




Source: IMF




Source: IMF




Source: IMF




Source: IMF




Source: IMF




Source: IMF

# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)


















# ការអនុវត្តថវិកា (Budget)

**ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៧-២០១៨**




Source: MEF

**ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៧-២០១៨**




**ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៧-២០១៨**




**ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៧-២០១៨**




**ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៧-២០១៨**




**ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៧-២០១៨**



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)

### Import and Export (mil.US$)




Source: Customs and Excise Department

### Import and Export Growth




Source: Customs and Excise Department

### Trade Balance and CA as % GDP




Source: National Bank of Cambodia, NBC, and Customs

### Export by Main Continents (mil.US$)




Souce: Customs and Excise Department, MEF
(including foreign currency exports )

### Export by Commodity Group ( in tonnes)




Souce: Customs and Excise Department, MEF

### Export Clothing and Rubber (mil.US$)




Souce: Customs and Excise Department, MEF

## <u>កំណត់សម្គាល់</u>

កៅស៊ូ÷

- កៅស៊ូTSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូSIR20, SMR20 និងSTR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ(កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូTSR20ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូលជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាមនិងចិន។
- កៅស៊ូRSS (Ribbed Smoked Sheets)បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទRSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុសម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់រថយន្ត និងដែលជាធាតុផ្សំលើស 50%នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅBrent, WTI និងDubai ជាប្រភេទប្រេងឆៅធុនស្រាល(Light Crude Oil)ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ ប្រភេទប្រេងBrentច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិកWTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីតDubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40o API
- Brent 38o API
- Dubai 32o API

**រៀបចំដោយ**

**នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*
*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២*
*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*
*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*
*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*